ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតអគ្គលេខាធិការដ្ឋានថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា
- យោងសំណើលេខ ០៥៣/២០ ស.ន.ក.ជ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់គណៈសង្ឃនាយក ស្តីពីការរៀបចំដំឡើងឋានៈ និងតែងតាំងមន្ត្រីសង្ឃជាន់ខ្ពស់ ក្នុងស្ថាប័នថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា និងបង្កើតអគ្គលេខាធិការដ្ឋាន

សម្រេច

មាត្រា១ ៖ ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា។

មាត្រា២ ៖ អគ្គលេខាធិការដ្ឋានថេរសភា នៃពុទ្ធសាសនា ជាសេនាធិការឱ្យថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយអគ្គលេខាធិការ ១អង្គ និងអគ្គលេខាធិការរង ២អង្គ។

មាត្រា៣ ៖ អគ្គលេខាធិការដ្ឋាន មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

-ដំណើរការកិច្ចការរដ្ឋបាលទូទៅរបស់ថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា

-សម្របសម្រួលការប្រព្រឹត្តទៅរបស់ថេរសភា នៃពុទ្ធសាសនា

-ទទួលសំណុំអធិករណ៍ពីគណៈសង្ឃនាយក និងរៀបចំឯកសារ ប្រគេនថ្នាក់ដឹកនាំថេរសភា នៃពុទ្ធសាសនា ដើម្បីដោះស្រាយ និងជំនុំជម្រះ

-រៀបចំដំណើរបេសកកម្មរបស់ថ្នាក់ដឹកនាំថេរសភា នៃពុទ្ធសាសនា

-ចាត់ចែងរៀបចំការប្រជុំរបស់ថេរសភា នៃពុទ្ធសាសនា
-រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីសង្ឃថេរសភារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ
-រៀបចំក្រុមចុះស្រាវជ្រាវស៊ើបអង្កេតអធិករណ៍តាមករណីជាក់ស្តែង
-ប្រមូលព័ត៌មានដែលទាក់ទងនឹងអធិករណ៍ពុទ្ធសាសនា
-ស្រាវជ្រាវ និងប្រមូលចងក្រងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ
-ធ្វើកំណត់ហេតុប្រជុំរបស់ថេរសភា នៃពុទ្ធសាសនា
-ធ្វើទំនាក់ទំនងជាមួយអាជ្ញាធរពាក់ព័ន្ធ និងតុលាការខាងអាណាចក្រ
-ការងារបញ្ជូនសំណុំអធិករណ៍ទៅថ្នាក់ដឹកនាំថេរសភា នៃពុទ្ធសាសនា
-ធ្វើទំនាក់ទំនងជាមួយលេខាធិការដ្ឋានគណៈសង្ឃនាយក
-ការងារទំនាក់ទំនងសាធារណៈ
-ការងារគ្រប់គ្រងបច្ចេកទេស សម្រាប់កម្មវិធីការងារជម្រះអធិករណ៍
-អនុវត្តការងារផ្សេងៗទៀត តាមការកំណត់នៃលិខិតបទដ្ឋានគតិយុត្ត
-ទទួលការងារផ្សេងៗទៀត តាមការចង្អុលបង្ហាញរបស់ប្រធានថេរសភា នៃពុទ្ធសាសនា
-ធ្វើរបាយការណ៍តាមរបបកំណត់ និងរបាយការណ៍ជំនាញ ជូនទៅគណៈសង្ឃនាយក

មាត្រា៤ ៖ បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៥ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.សៅរ៍.១៣កើត.ខែ.ផល្គុន....ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី.......៧.....ខែ.មីនា.......ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

-សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ
-ថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ
-ដូចមាត្រា៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ